ព្រឹត្តិបត្រ ស្តីពីបញ្ហាអាជីវកម្ម

កម្ពុជា

លេខ ១៦ តុលា ២០០៨

# ការពង្រឹងវិស័យហិរញ្ញវត្ថុនៅកម្ពុជា



*វិស័យហិរញ្ញវត្ថុត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយ ថាជាគន្លឹះសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ឧស្សាហកម្មហិរញ្ញវត្ថុផ្តល់ដល់អាជីវកម្មនូវហិរញ្ញប្បទានដែលពួកគេត្រូវការដើម្បីពង្រីកមុខរបរ បង្កើតការងារ និងអភិវឌ្ឍធនធានមនុស្ស រួមចំណែកបង្កើនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការកៀងគរធនធាន និងការបង្វែរធនធានទាំងនោះទៅក្នុងទិសដៅវិនិយោគដែលមានប្រយោជន៍ ។*

*ដោយទទួលស្គាល់ពីតួនាទីដ៏មានសារៈសំខាន់របស់ឧស្សាហកម្មហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ និងបានធ្វើកំណែទម្រង់ជាច្រើនក្នុងវិស័យនេះតាំងពីទសវត្សឆ្នាំ ១៩៩០ មកម្លេះ ។ ដោយមានការគាំទ្រពីដៃគូរអភិវឌ្ឍន៍ និងដោយមានការចូលរួមយ៉ាងសកម្មពីផ្នែកឯកជនផងនោះ កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់បាន បង្កើនទំនុកចិត្តលើវិស័យហិរញ្ញវត្ថុ ហើយបានធ្វើឱ្យការផ្តល់ប្រាក់កម្ចីដោយស្ថាប័នហិរញ្ញវត្ថុបានកើនឡើងយ៉ាងខ្លាំង ពី **២៨០ លានដុល្លារអាមេរិក** នៅក្នុងឆ្នាំ ២០០២ ដល់ជិត **១,៦ ពាន់លានដុល្លារអាមេរិក** នៅក្នុងឆ្នាំ ២០០៧* [១] ។

កំណើននៃការផ្តល់ប្រាក់កម្ចីនៅក្នុងរយៈពេលដ៏ខ្លីនេះ មានទំហំគួរសំគាល់ ប៉ុន្តែបើយើងប្រៀបធៀបចំនួននេះទៅនឹងទំហំសេដ្ឋកិច្ចទាំងមូលវិញនោះ ចំនួនប្រាក់កម្ចីនេះនៅមានកម្រិតទាបណាស់ ។ នៅឆ្នាំ ២០០៧ ប្រាក់កម្ចីសរុប មានចំនួនប្រមាណតែ ១៨% នៃផលទុនសរុបប៉ុណ្ណោះ[២] ។ ចំនួននេះនៅមានកម្រិតទាបណាស់ ធៀបទៅនឹងប្រទេសជិតខាង ។ នេះមានន័យថា ផ្នែកឯកជននៅកម្ពុជានៅតែជួបប្រទះការលំបាកក្នុងការទទួលបានឥណទាន ។

ដើម្បីអាចផ្តល់ឱ្យក្រុមហ៊ុនឯកជននូវហិរញ្ញប្បទានដែលពួកគេត្រូវការដើម្បីរីកលូតលាស់ និងសម្រេចបានតាមសក្តានុពលរបស់ពួកគេ រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតឱ្យមានបរិយាកាសល្អមួយ ដើម្បីឱ្យស្ថាប័នហិរញ្ញវត្ថុអាចផ្តល់ផលិតផលហិរញ្ញវត្ថុច្រើនប្រភេទទៀត លើសពីការផ្តល់ប្រាក់កម្ចីដែលផ្អែកលើទ្រព្យបញ្ចាំជាដី ឬអគារនោះ ។ នៅក្នុងព្រឹត្តិប័ត្រលេខនេះ យើងពិភាក្សាពីបទបញ្ញតិចាំបាច់លើវិស័យសំខាន់ៗចំនួនបី ដែលត្រូវមាន ឬត្រូវកែលំអនៅក្នុងឧស្សាហកម្មហិរញ្ញវត្ថុ ក្នុងនោះរួមមាន *ព័ត៌មានឥណទាន ប្រតិបត្តិការដែលមានកិច្ចធានា និង ភតិសន្យា* ។

International Finance Corporation
World Bank Group

**កំណើនប្រាក់កម្ចី ២០០២ -២០០៧**




[១] ធនាគារជាតិនៃកម្ពុជា

[២] គណនាដោយផ្អែកទៅលើទិន្នន័យដែលទទួលបានពីធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ

**ព្រឹត្តិបត្រស្តីពីបញ្ហាអាជីវកម្ម** ផ្តល់ជូនលោកអ្នកដែលមានចំណាប់អារម្មណ៍ពីរឿងរ៉ាវទាក់ទិននឹងកិច្ចការអាជីវកម្មនូវសេចក្តីសង្ខេបខ្លីៗ និងសេចក្តីវិភាគលើប្រធានបទដែលពាក់ពន្ធ័នឹងបរិយាកាសអាជីវកម្មនៅកម្ពុជា ។ ព្រឹត្តិបត្រ័នេះមានរួមបញ្ចូលទាំងមតិ និងយោបល់ផ្សេងៗ របស់មជ្ឈដ្ឋានពាក់ពន្ធ័ផងដែរ ។

ព្រឹត្តិបត្រ័នេះ ត្រូវបានបោះពុម្ពឡើងដោយមានការសហការ និង ជួយឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាស្ថាប័នពហុជំនួយគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធ្វើការអភិវឌ្ឍន៍វិស័យឯកជន នៅក្នុងប្រទេសវៀតណាម កម្ពុជា និងសាធារណៈរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ ។ ម្ចាស់ជំនួយរួមមាន អូស្រ្តាលី កាណាដា សហគមអឺរ៉ុប ហ្វាំងឡង់ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ អៀឡង់ ជប៉ុន នូវែលហ្សេឡង់ ហូឡង់ ណរវែស ស៊ុយអែត និងស្វីស ។

មតិ ឬយោបល់ទាំងឡាយដែលចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនតំណាងឱ្យទស្សនៈជាផ្លូវការរបស់ IFC ទេ វាគ្រាន់តែផ្តល់ជាព័ត៌មាន យោងបន្ថែមតែប៉ុណ្ណោះ ។

## ទិន្នន័យឥណទានដែលប្រសើរជាងមុន តាមរយៈការិយាល័យឥណទានឯកជន អាចជួយបង្កើនលទ្ធភាពរបស់សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជាក្នុងការទទួលបានឥណទាន

ការផ្តល់ឥណទានសម្រាប់ផ្នែកឯកជន ជាពិសេសសម្រាប់បុគ្គល និងអាជីវកម្មតូចៗ ត្រូវរារាំងដោយសារតែអ្នកផ្តល់ឥណទានមិនអាចរកព័ត៌មានឥណទានរបស់បុគ្គល ឬអាជីវកម្មទាំងនោះបាន។ កង្វះខាតព័ត៌មានឥណទាន បង្កើនហានិភ័យ និងភាពមិនប្រាកដប្រជាយ៉ាងច្រើនសម្រាប់អ្នកផ្តល់ឥណទាន ធ្វើឱ្យពួកគេសំរេចចិត្តមិនផ្តល់ប្រាក់កម្ចី លុះត្រាណាតែអ្នកខ្ចីមានដីធ្លី និងអគារដែលមានតម្លៃខ្ពស់លើសពីចំនួនប្រាក់ដែលចង់ខ្ចី មកដាក់ជាទ្រព្យបញ្ចាំ។

កម្មវិធីអភិវឌ្ឍន៏សហគ្រាសធុនតូច និងមធ្យមរបស់ធនាគារអភិវឌ្ឍន៏អាស៊ីបានកំណត់ថា កង្វះព័ត៌មានឥណទាន ជាភាពខ្វះចន្លោះដ៏ធ្ងន់ធ្ងរមួយ នៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា ហើយវាក៏ជាមូលហេតុចម្បងមួយ ដែលធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមក៏ដូចជាបុគ្គល មានការពិបាកក្នុងការទទួលបានហិរញ្ញប្បទាន ដែលពួកគេត្រូវការដែរ។

ដើម្បីជំរុញឱ្យមានព័ត៌មានឥណទាន ធនាគារជាតិនៃកម្ពុជា ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៏អាស៊ី បានចាប់ផ្តើមគម្រោង សាកល្បងបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅក្នុងឆ្នាំ ២០០៤ ដោយមានការសហការពី សមាគមធនាគារនៅប្រទេសកម្ពុជា និងធនាគារដែលចូលរួមមួយចំនួនទៀត។ ប្រព័ន្ធព័ត៌មានឥណទានដែលបានចាប់ផ្តើមដំណើរការ តាំងពីឆ្នាំ ២០០៦ មកនោះ ប្រមូល និងចែករំលែកតែព័ត៌មានឥណទានអវិជ្ជមានប៉ុណ្ណោះ ហើយការប្រមូល និងចែករំលែកនោះទៀតសោតក៏ធ្វើឡើងតែក្នុងចំណោមសមាជិកនៃប្រព័ន្ធនេះដែរ។

ប្រព័ន្ធនេះបានដំណើរការនៅធនាគារជាតិនៃកម្ពុជា អស់រយៈពេលជាងពីរឆ្នាំមកហើយ ប៉ុន្តែមកទល់នឹងពេលនេះ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានឥណទាននេះនៅមានកម្រិតតិចតួចនៅឡើយ។ ការណ៏នេះកើតឡើងដោយសារតែប្រព័ន្ធនេះ ផ្ទុក និងចែករំលែក តែព័ត៌មានអវិជ្ជមានតែប៉ុណ្ណោះ ដែលនេះមិនឆ្លើយតបទៅនឹងតំរូវការរបស់ស្ថាប័នហិរញ្ញវត្ថុដែលត្រូវការព័ត៌មានផ្សេងៗទៀត លើសពីព័ត៌មានអវិជ្ជមានដើម្បីវាយតម្លៃ និងធ្វើការសំរេចចិត្តក្នុងការផ្តល់ប្រាក់កម្ចី។ ប្រព័ន្ធនេះនឹងផ្តល់អត្ថប្រយោជន៏ច្រើន ហើយស្ថាប័នហិរញ្ញវត្ថុនឹងប្រើប្រាស់វាច្រើនជាងនេះ ប្រសិនបើវារួមបញ្ចូលទាំងព័ត៌មានវិជ្ជមានផ្សេងៗទៀតដូចជា បំណុលដែលអ្នកសុំខ្ចីប្រាក់កំពុងមាន ចារិតលក្ខណៈក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់គេ និងការបង់ថ្លៃចំណាយប្រចាំខែផ្សេងៗទៀតដូចជា ប័ណ្ណឥណទាន សេវាទូរស័ព្ទ និងថ្លៃអគ្គីសនីជាដើម។ បើសិនជាមាន ព័ត៌មានបែបនេះ ស្ថាប័នហិរញ្ញវត្ថុ មិនត្រឹមតែអាចត្រួតពិនិត្យនឹងជំរុះបុគ្គល ឬអាជីវកម្មណាដែលមានបំណុលមិនល្អនោះទេ ពួកគេក៏នឹងអាចផ្តល់ប្រាក់កម្ចីដល់អ្នកដែលមានប្រវត្តិឥណទានល្អ ក្នុងលក្ខខណ្ឌដែលប្រសើរជាងទៀតផង។

បទពិសោធន៏អន្តរជាតិបានបង្ហាញថា ការិយាល័យឥណទានឯកជន គឺជាយន្តការដែលល្អ និងមានចិរភាព ក្នុងការប្រមូល និងផ្តល់ឱ្យស្ថាប័នហិរញ្ញវត្ថុ នូវព័ត៌មានឥណទានពេញលេញ គ្រប់ជ្រុងជ្រោយ។ ការិយាល័យឥណទាន ឯកជនអាចប្រមូល រក្សា និងចែករំលែកទាំងព័ត៌មានវិជ្ជមាន និងអវិជ្ជមាន បានប្រសើរជាង ហើយក៏អាចផ្តល់សេវាបន្ថែមនានាដូចជា ការរៀបចំពាក្យសុំឥណទាន និងការផ្តល់សូចនាករសំរាប់វាយតម្លៃឥណទានជាដើម។ ដូច្នេះ រដ្ឋាភិបាលគួរផ្តល់អាទិភាពដល់ ការបង្កើតក្របខ័ណ្ឌគតិយុត្តិសំខាន់ៗនានា ដើម្បីជ្រោមជ្រែងការបង្កើតការិយាល័យឥណទានឯកជននៅប្រទេសកម្ពុជា ដែលអាចចែករំលែកព័ត៌មានឥណទាន លើសពីអ្វីដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទានបច្ចុប្បន្ននេះអាចធ្វើបាន។

*ប្រព័ន្ធព័ត៌មានឥណទាន ត្រូវបានដាក់ឱ្យសាកល្បងចាប់តាំងពីឆ្នាំ ២០០៦ មកម្លេះ។ ប៉ុន្តែមកទល់នឹងពេលនេះ នៅមានចំនុចមួយចំនួន ដែលត្រូវធ្វើការកែលំអ ដើម្បីឱ្យប្រព័ន្ធនេះអាចឆ្លើយតបទៅនឹងតម្រូវការ របស់អតិថិជនប្រកបដោយប្រសិទ្ធភាពខ្ពស់។ បច្ចុប្បន្ននេះកត្តាដែលរួមចំណែក កាត់បន្ថយប្រសិទ្ធភាពរបស់ប្រព័ន្ធនេះ រួមមាន (១) សមាជិកភាពនៃប្រព័ន្ធនេះ ឈរលើមូលដ្ឋានស្ម័គ្រចិត្ត (២) ប្រព័ន្ធនេះចែករំលែកតែព័ត៌មានឥណទានអវិជ្ជមាន ដែលមិនសូវមានអត្ថប្រយោជន៏សម្រាប់ស្ថាប័នហិរញ្ញវត្ថុ (៣) ប្រព័ន្ធមានដំណើរការយឺត ដែលការណ៏នេះបង្ករការលំបាកដល់សមាជិក ក្នុងការបញ្ចូលព័ត៌មាន និងធ្វើឱ្យសមាជិកខ្លះមិនបញ្ចូលព័ត៌មានតែម្តង។*

*បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាកំពុងធ្វើការពិភាក្សាទៅលើ លទ្ធភាពនៃការបង្កើតការិយាល័យព័ត៌មានឥណទានឯកជន។ យើងកំពុងធ្វើការជាមួយកម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគ្គង នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC MPDF) ក្នុងការអង្កេតអំពីការប្រើប្រាស់ប្រព័ន្ធ ចែករំលែកព័ត៌មានឥណទានបច្ចុប្បន្ន និងធ្វើសម្ភាសន៏ជាមួយ គ្រឹះស្ថានធនាគារ មីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សេងៗ (ដូចជាក្រុមហ៊ុនអគ្គីសនី និងរដ្ឋករទឹកជាដើម) ដើម្បីយល់ដឹងអំពីការចាប់អារម្មណ៏ និងលទ្ធភាពរបស់ពួកគេក្នុងការផ្តល់ទិន្នន័យ។ ក្រោយពីការអង្កេតចប់ នឹងមានការដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្ត។ ដូច្នេះខ្ញុំមិនអាចនិយាយបានថា ការិយាល័យព័ត៌មានឥណទានឯកជន នឹងត្រូវបានបង្កើតនាពេលណានោះទេ។ តែគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជាគាំទ្រការបង្កើតការិយាល័យនេះ។*

**ឯកឧត្តម ផាន់ ហូ អគ្គលេខាធិការ នៃអង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជា**
**ធនាគារជាតិនៃកម្ពុជា**

*ប្រព័ន្ធនេះអាចដំណើរការបានល្អ លុះត្រាតែមានការចូលរួមពីភាគី ផ្សេងទៀតក្រៅពីធនាគារ ហើយវានឹងផ្តល់អត្ថប្រយោជន៏ច្រើន ប្រសិនបើស្ថាប័នរបស់រដ្ឋាភិបាល ដូចជាក្រុមហ៊ុនអគ្គីសនីកម្ពុជា និងក្រុមហ៊ុនទូរគមនាគមន៏កម្ពុជា រួមចំណែកផ្តល់ព័ត៌មានទៅក្នុងប្រព័ន្ធនេះ។*

**លោក *Gary Runciman* នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម**
***ANZ Royal Bank***

*ប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ ត្រូវការការិយាល័យព័ត៌មានឥណទានឯកជនដែលមានប្រសិទ្ធភាព។ បុគ្គល និងអាជីវកម្មកាន់តែច្រើនត្រូវការហិរញ្ញប្បទាន ប៉ុន្តែស្ថាប័នហិរញ្ញវត្ថុ មានការពិបាកក្នុងការឆ្លើយតបទៅនឹងតម្រូវការទាំងនោះ ដោយសារតែកង្វះខាតព័ត៌មានឥណទានដែលគួរឱ្យជឿជាក់បាន ដើម្បីជួយធនាគារក្នុងការសម្រេចចិត្ត។ ការិយាល័យឥណទានឯកជន អាចនឹងជួយយ៉ាងច្រើនក្នុងការបង្កើតប្រវត្តិឥណទានដ៏រឹងមាំមួយ ដោយផ្អែកលើព័ត៌មានច្រើនប្រភេទ។ ប៉ុន្តែ ដើម្បីអាចបង្កើតការិយាល័យឥណទានឯកជនបាន យើងចាំបាច់ត្រូវកែសម្រួលក្របខ័ណ្ឌគតិយុត្តិមួយចំនួន ដូចជាច្បាប់ស្តីពីធនាគារ ដែលនាពេលបច្ចុប្បន្ន មិនអនុញ្ញាតឱ្យស្ថាប័នហិរញ្ញវត្ថុ ធ្វើការបង្ហាញព័ត៌មានរបស់អតិថិជន។ ច្បាប់នេះ ត្រូវបកស្រាយឱ្យច្បាស់ថា តើព័ត៌មានអ្វីដែលអាចបង្ហាញបាន និងព័ត៌មានអ្វីដែលមិនអាចបង្ហាញបាន។*

**លោក ហួត អៀងតុង អ្នកចាត់ការទូទៅ ហត្ថាកសិករលីមីតធីត**
**និងជាប្រធានសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា**

*ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន នឹងមានប្រយោជន៏ ប្រសិនបើអ្នកគ្រប់គ្នាប្រើប្រាស់វា ហើយចូលរួមផ្តល់ព័ត៌មាន។ បច្ចុប្បន្ននេះ មានស្ថាប័នហិរញ្ញវត្ថុតែមួយចំនួនតូចប៉ុណ្ណោះដែលចូលរួម ហើយកង្វះការចូលរួមនេះ បានកាត់បន្ថយអត្ថប្រយោជន៏របស់ប្រព័ន្ធនេះ។ លើសពីនេះទៀត ប្រព័ន្ធនេះមានដំណើរការយឺត ធ្វើឱ្យយើងត្រូវចំណាយពេលយ៉ាងច្រើនក្នុងការបញ្ចូលព័ត៌មាន ហើយនៅពេលដែលយើងត្រូវការជំនួយពេលជួបបញ្ហាក្នុងការបញ្ចូលពតិមាននោះ ការឆ្លើយតបមានលក្ខណៈយឺតយ៉ាវ។ បញ្ហាមួយទៀតដែលយើងជួបប្រទះ គឺប្រព័ន្ធនេះតម្រូវឱ្យមានលេខលិខិតឆ្លងដែន និងលេខអត្តសញ្ញាណប័ណ្ណ។ លក្ខខ័ណ្ឌតម្រូវនេះមិនមានលក្ខណៈសមស្របនៅក្នុង ប្រទេសកម្ពុជានាពេលបច្ចុប្បន្នឡើយ។ អតិថិជនរបស់យើង ភាគច្រើនស្ថិតនៅទីជនបទ ដែលពួកគេភាគច្រើនមិនមានអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនឡើយ គ្រួសារខ្លះ សូម្បីតែសៀវភៅគ្រួសារក៏មិនមានផង។ យើងត្រូវមានដំណោះស្រាយនៅពេលដែលជួបកាលៈទេសៈបែបនេះ។*

**លោក អ៊ិន ស៊ីផាន់ នាយកប្រតិបត្តិឥណទាននៃធនាគារអេស៊ីលីដា**

## ***សារៈសំខាន់នៃការអនុវត្តច្បាប់ស្តីពី ប្រតិបត្តិការមានកិច្ចធានា ប្រកបដោយប្រសិទ្ធិភាព***

ជាទូទៅ ធនាគារនៅក្នុងប្រទេសកម្ពុជាសំរេចផ្តល់ប្រាក់កម្ចី លុះត្រាតែអ្នកខ្ចីមានទ្រព្យបញ្ចាំជាអចលនទ្រព្យ ដូចជាដី និងអគារ ហើយអចលនទ្រព្យទាំងនេះត្រូវមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ឬទីរួមខេត្តធំណាមួយ ។ លើសពីនេះទៀត គេឱ្យខ្ចីត្រឹមតែពី ៣០% ទៅ ៥០% នៃតម្លៃសរុបរបស់ទ្រព្យបញ្ចាំនោះប៉ុណ្ណោះ ។ ចលនទ្រព្យ ឬទ្រព្យអរូបិយដូចជា យានយន្ត គ្រឿងម៉ាស៊ីន គណនីអតិថិជន ឬសន្និធិ(ស្តុក) មិនត្រូវបានទទួលយកធ្វើជាទ្រព្យបញ្ចាំទេ ព្រោះធនាគារខ្លាចថា ពួកគេនឹងមិនអាចរឹបអូស ឬកាន់កាប់ទ្រព្យទាំងនោះបាន ក្នុងករណីដែលអ្នកខ្ចីមិនព្រមសងប្រាក់របស់ពួកគេ ។ បញ្ហានេះ បានកាត់បន្ថយលទ្ធភាពរបស់អាជីវកម្មដែលមិនមានអចលនទ្រព្យសំរាប់បញ្ចាំ ក្នុងការទទួលបានហិរញ្ញប្បទានដែលចាំបាច់សម្រាប់ការពង្រីកអាជីវកម្ម របស់ពួកគេ ។ បញ្ហានេះមានផលប៉ះពាល់ជាអវិជ្ជមានសម្រាប់សេដ្ឋកិច្ចទាំងមូល ដោយហេតុថា វារាំងខ្ទប់អាជីវកម្មទាំងឡាយមិនឱ្យរីកលូតលាស់ និងមិនអាចចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមសក្តានុពលភាពដែលមាន ។

ដោយយល់ដឹងពីតម្រូវការរបស់អាជីវកម្ម និងរបស់បុគ្គលក្នុងការខ្ចីប្រាក់ដោយផ្អែកលើចលនទ្រព្យ ឬទ្រព្យអរូបិយ ជាទ្រព្យបញ្ចាំនោះ រដ្ឋាភិបាលបាន និងកំពុងធ្វើការលើក្របខ័ណ្ឌគតិយុត្តិមួយដែលធានាថា ធនាគារមានសិទ្ធិរឹបអូសទ្រព្យទាំងនោះប្រកបដោយប្រសិទ្ធភាព ប្រសិនបើអ្នកខ្ចីមិនបានសងបំណុល ។

ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ត្រូវបានអនុម័តនៅក្នុងខែ ឧសភា ឆ្នាំ ២០០៧ ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីផ្តល់មូលដ្ឋានគតិយុត្តិសម្រាប់ការប្រើប្រាស់ចលនទ្រព្យ និងទ្រព្យអរូបិយធ្វើជាទ្រព្យបញ្ចាំ ។ ច្បាប់នេះ មានលក្ខណៈលំអិតច្បាស់លាស់ និងអនុញ្ញាតឱ្យម្ចាស់បំណុលរឹបអូសទ្រព្យប្រចាំ ប្រសិនបើកូនបំណុលមិនបានបំពេញកាតព្វកិច្ច សងប្រាក់កម្ចីរបស់ខ្លួនត្រឹមត្រូវ ។ ច្បាប់នេះក៏បានកំណត់យ៉ាងទូលំទូលាយផងដែរ ពីចលនទ្រព្យ និងទព្យអរូបិយជាច្រើនដែលអាចប្រើប្រាស់ជាវត្ថុបញ្ចាំបាន ហើយក៏ផ្តល់នូវវិធានយ៉ាងច្បាស់លាស់ អំពីសិទ្ធអាទិភាពរបស់ម្ចាស់បំណុល ។ លើសពីនេះទៀត ច្បាប់ប្រតិបត្តិការមានកិច្ចធានានេះក៏បានបង្កើតប្រព័ន្ធចុះបញ្ជីដោយអ៊ីនធឺរណេត ដែលមានលក្ខណៈសាមញ្ញ ងាយស្រួលប្រើ ចំណាយពេល និងថវិការតិចសំរាប់ការចុះលើទ្រព្យបញ្ចាំ ។ ក្នុងនាមជាអាជ្ញាធរទទួលបន្ទុក ក្រសួងពាណិជ្ជកម្មបានបង្កើតប្រព័ន្ធចុះបញ្ជីនេះ ក្រោមការឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី ។ ក្រៅពីការចុះបញ្ជីចលនទ្រព្យ និងទ្រព្យអរូបីយដែលខ្លួនបានទទួលយកជាវត្ថុបញ្ចាំហើយនោះ ស្ថាប័នហិរញ្ញវត្ថុក៏អាចស្រាវជ្រាវរកមើលការទាមទាដែលកំពុងមានលើទ្រព្យទាំងនោះ តាមរយៈប្រព័ន្ធនេះផងដែរ ។ ក្នុងករណីដែលកូនបំណុលខកខានមិនបានសងបំណុលតាមកិច្ចសន្យា ហើយមានជម្លោះក្នុងចំណោមម្ចាស់បំណុលនោះ បញ្ជីក្នុងប្រព័ន្ធនេះនឹងត្រូវប្រើប្រាស់ ដើម្បីកំណត់ថា នរណាជាអ្នកមានសិទ្ធិអាទិភាពលើវត្ថុបញ្ចាំ ។

ស្ថាប័នហិរញ្ញវត្ថុនានាក៏ដូចជាភាគីអ្នកខ្ចីដែរ យល់ឃើញថា ការអនុម័តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានេះ ជាជំហានដ៏សំខាន់មួយដែលនឹងធ្វើឱ្យលទ្ធភាពទទួលបានហិរញ្ញប្បទាននៅកម្ពុជាមានភាពល្អប្រសើរឡើង ។ ប្រសិនបើច្បាប់នេះអនុវត្តទៅប្រកបដោយប្រសិទ្ធិភាពនោះ សហគ្រាសជំនួញក៏ ដូចជាបុគ្គលឯកជននានាដែលមិនមានដីធ្លី និងអគារ ប៉ុន្តែមានចលនទ្រព្យ និងទ្រព្យអរូបីដែលមានតម្លៃនឹងមានភាពងាយស្រួលជាងមុនក្នុងការខ្ចីប្រាក់ក្នុងតំលៃសមស្រប ។

ទោះជាយ៉ាងណាក្តី ក្របខ័ណ្ឌច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានានេះនៅមិនទាន់បានអនុវត្តប្រកបដោយប្រសិទ្ធិភាពនៅឡើយ ហើយក៏មិនទាន់ទទួលបានទំនុកចិត្តពីស្ថាប័នហិរញ្ញវត្ថុនានានៅឡើយដែរ ។ ច្បាប់នេះត្រូវបានអនុម័តជាងមួយឆ្នាំមកហើយ ប៉ុន្តែមកទល់នឹងពេលនេះ ការផ្តល់ប្រាក់កម្ចីដោយផ្អែកទៅលើចលនទ្រព្យ និងទ្រព្យអរូបីមានតិចតួចណាស់ ។ បើយោងទៅតាមធនាគារមួយចំនួនដែលបានផ្តល់សម្ភាសន៍សម្រាប់ព្រឹត្តិប័ត្រលេខនេះ មានបញ្ហាសំខាន់ៗពីរគឺ ៖

- *ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា និងក្រមរដ្ឋប្បវេណីមិនមានភាព ចុះសម្រុងគ្នាស្តីពីនិតិវិធីក្នុងការរឹបអូសទ្រព្យដែលបានដាក់បញ្ចាំក្នុងករណីដែលកូនបំណុលមិនអាចបំពេញកាតព្វកិច្ចបំណុលៈ* ក្រោមច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចការធានា ស្ថាប័នហិរញ្ញវត្ថុអាចរឹបអូសទ្រព្យបញ្ចាំ ដោយមិនចាំបាច់ឆ្លងកាត់ប្រព័ន្ធតុលាការ ប្រសិនបើអ្នកខ្ចីខកខានមិនបានសងបំណុល ។ ដោយឡែកនៅក្រោមក្រមរដ្ឋប្បវេណីវិញ ដំណើរការនេះត្រូវធ្វើទៅតាមប្រព័ន្ធតុលាការ ។
- *ទំនុកចិត្តរបស់ស្ថាប័នហិរញ្ញវត្ថុ លើការចុះបញ្ជីតាមអ៊ីនធឺណេតរបស់ប្រតិបត្តិការមានកិច្ចធានានៅមានកម្រិតនៅឡើយៈ* កង្វះការយល់ដឹងពីការចុះបញ្ជីតាមអ៊ីនធឺរណេតនេះ ធ្វើឱ្យស្ថាប័នហិរញ្ញវត្ថុនានាមិនទាន់មានទំនុកចិត្តទៅលើប្រព័ន្ធថ្មីនេះនៅឡើយ ។ ជាទូទៅគេនៅតែចង់បានជាក្រដាសស្នាមដែលមានប្រថាប់ត្រាដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបញ្ជាក់ពីការបានចុះបញ្ជីនៃទ្រព្យបញ្ចាំក្នុងប្រតិបត្តិការមានកិច្ចធានានោះ ។

ដូច្នេះ យើងអាចឃើញយ៉ាងច្បាស់ថា រដ្ឋាភិបាលចាំបាច់ត្រូវប្រឹងប្រែងបន្ថែមទៀត ដើម្បីបង្កើនទំនុកចិត្តរបស់ស្ថាប័នហិរញ្ញវត្ថុនានា លើការអនុវត្តន៍ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា និងលើប្រព័ន្ធចុះបញ្ជីដោយអ៊ីនធឺណេត ដែលអាចឱ្យពួកគេអាចស្វែងរក និងចុះបញ្ជីទ្រព្យបញ្ចាំដែលជាចលនទ្រព្យ និងទ្រព្យអរូបីយដោយងាយស្រួល និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

*ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានាមានអត្ថប្រយោជន៍ណាស់ ហើយប្រព័ន្ធចុះបញ្ជីដែលដាក់ឱ្យដំណើរការសព្វថ្ងៃក៏ល្អណាស់ដែរ ។ ប៉ុន្តែ យើងនៅមានការបារម្ភលើភាពមិនចុះសម្រុងគ្នារវាងច្បាប់នេះ និងក្រមរដ្ឋប្បវេណី ។ នៅពេលដែលមានបញ្ហាជាមួយកូនបំណុល ធនាគារត្រូវតែអាចអនុវត្តសកម្មភាពចាំបាច់ផ្សេងៗដោយឆាប់រហ័សដើម្បីការពារអត្ថប្រយោជន៍របស់គេ ។ ពេលណាដែលបញ្ហានៃការមិនចុះសម្រុងគ្នារវាងច្បាប់ទាំងពីរនេះត្រូវបានដោះស្រាយ ហើយយើងអាចរកបាននូវព័ត៌មានហិរញ្ញវត្ថុ ដែលមានការត្រួតពិនិត្យត្រឹមត្រូវនោះ យើងនឹងអាចផ្តល់ប្រាក់កម្ចីដោយផ្អែកលើទ្រព្យបញ្ចាំផ្សេងៗ ក្រៅពីដីធ្លី និងអគារ ។*

**លោក Gary Runciman នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ANZ Royal Bank**

*ភាពមិនចុះសម្រុងគ្នារវាងច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា និងក្រមរដ្ឋប្បវេណី ត្រូវតែធ្វើការដោះស្រាយជាចាំបាច់ ហើយកិច្ចប្រឹងប្រែងដើម្បីបង្កើនទំនុកចិត្តសាធារណៈជនទូទៅមកលើប្រព័ន្ធចុះបញ្ជីតាមអ៊ីនធឺរណេតក៏ចាំបាច់ដែរ ។ គេត្រូវធ្វើអោយប្រាកដថាដំណើរការចុះបញ្ជី និងការគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តទៅដោយត្រឹមត្រូវ និងមានតម្លាភាព ។*

**លោក អ៊ិន ស៊ីផាន់ នាយកប្រតិបត្តិឥណទាន នៃធនាគារអេស៊ីលីដា**

*ចាប់តាំងពីច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ត្រូវបានអនុម័តមក មានកិច្ចសន្យាប័ណ្ណតំណាងទ្រព្យចំនួនជាង ១០០ ករណីហើយ បានចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីរបស់យើង ។ ដូច្នេះខ្ញុំអាចនិយាយបានថា ក្របខ័ណ្ឌនៃប្រតិបត្តិការមានកិច្ចធានាមានការរីកចំរើនទៅមុខហើយ គ្រាន់តែវាមានដំណើរទៅដោយយឺតៗ ។ ការយឺតយ៉ាវនេះ មិនគួរជាការភ្ញាក់ផ្អើលទេ ព្រោះនេះជាអ្វីមួយដែលថ្មីស្រឡាងនៅក្នុងសង្គមកម្ពុជា ដូច្នេះការយល់ដឹងអំពីបញ្ហានេះនៅមានកំរិតសូម្បីតែក្នុងចំណោមធនាគារ និងស្ថាប័នហិរញ្ញវត្ថុនានា ។ ចំពោះប្រព័ន្ធចុះបញ្ជីតាមអ៊ីនធឺរណេតនោះក៏ដូចគ្នាដែរ គឺវាជាប្រព័ន្ធថ្មី សាធារណៈជនមិនទាន់យល់ជ្រួតជ្រាបពីការប្រើប្រាស់របស់វានៅឡើយ ដូច្នេះទំនុកចិត្តមកលើប្រព័ន្ធនេះក៏នៅមានកំរិតដែរ ។ យើងយល់ច្បាស់ពីកង្វះខាតនេះ ហើយយើងកំពុងពង្រីកការផ្សព្វផ្សាយច្បាប់នេះបន្ថែម ជាពិសេសនៅថ្នាក់ខេត្ត ។*

*ចំពោះភាពមិនចុះសម្រុងគ្នាជាមួយនឹងក្រមរដ្ឋប្បវេណីនោះ ខ្ញុំគិតថាមិនមែនជាបញ្ហាធំនោះទេ ។ នៅក្នុងច្បាប់ គេចែងច្បាស់លាស់ណាស់ថា ករណីបែបណាដែលត្រូវឆ្លងកាត់ និងករណីបែបណាដែលមិនចាំបាច់ឆ្លងកាត់តាមប្រព័ន្ធតុលាការ ។ បញ្ហាគឺស្ថិតនៅត្រង់នីតិវិធីអនុវត្តប៉ុណ្ណោះ យើងត្រូវការអនុក្រឹត្យមួយដើម្បីបកស្រាយបញ្ជាក់ពីបញ្ហានេះ ។ បច្ចុប្បន្ននេះ ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងជួយយើងរៀបចំអនុក្រឹត្យនេះ ។ ជាការឆ្លើយតបទៅនឹងកង្វះទំនុកចិត្តលើការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីតាមអ៊ីនធឺណេតនោះ បច្ចុប្បន្ននេះយើងអាចបត់បែនតាមតម្រូវការរបស់ស្ថាប័នហិរញ្ញវត្ថុ ។ បើសិន ជាគេចង់បានការបញ្ជាក់ជាលិខិតស្នាមនោះ យើងអាចបោះពុម្ពឯកសារនៃការចុះបញ្ជីចេញពីប្រព័ន្ធហើយយើងបោះត្រាបញ្ជាក់ ។*

**ឯកឧត្តម ម៉ៅ ថូរ៉ា រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម**

## ភតិសន្យាអាចជួយឱ្យសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ទទួលបានហិរញ្ញប្បទានដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន

ភតិសន្យា សំដៅទៅលើការបង់ប្រាក់ ដើម្បីមានសិទ្ធិប្រើប្រាស់សម្ភារៈ និងបរិក្ខាដូចជាយានយន្ត ឬគ្រឿងម៉ាស៊ីននានាដោយពុំចាំបាច់ទិញ ។ ភតិសន្យានេះជួយឱ្យសហគ្រាសជំនួញនានាអាចពង្រឹង និងពង្រីកប្រតិបត្តិការរបស់ខ្លួនដោយពុំចាំបាច់ខ្ចីប្រាក់ច្រើនសម្រាប់ចំណាយក្នុងការទិញសម្ភារៈ ឬបរិក្ខាដែលគេត្រូវការ ។ ជាជំនួសវិញ ធនាគារ ឬក្រុមហ៊ុនដែលជាម្ចាស់នៃសម្ភារៈ ឬបរិក្ខាទាំងនោះ ជួលឱ្យទៅអាជីវកម្ម ឬអ្នកដែលត្រូវការប្រើប្រាស់វា ។ ដំណើរការបែបនេះ អាចជួយអាជីកម្មបានយ៉ាងច្រើន ជាពិសេសសហគ្រាសខ្នាតតូច និងមធ្យមដែល ខ្វះទ្រព្យបញ្ចាំចាំបាច់ដើម្បីទទួលបានហិរញ្ញប្បទានសំរាប់ពង្រីកប្រតិបត្តិការ ។ ដូច្នេះ ភតិសន្យាអាចជួយបង្កើនល្បឿនកំណើននៃសហគ្រាសជំនួញ និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។

ច្បាប់ស្តីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុដែលត្រូវបានប្រកាសឱ្យប្រើ តាំងពីឆ្នាំ ១៩៩៩ អនុញ្ញាតឱ្យធនាគារនៅក្នុងប្រទេសកម្ពុជាធ្វើប្រតិបត្តិការភតិសន្យាបាន ប៉ុន្តែបញ្ញត្តិនៃច្បាប់នេះមានលក្ខណៈទូទៅពេក និងគ្មានក្របខ័ណ្ឌច្បាប់ លំអិតច្បាស់លាស់ដើម្បី គ្រប់គ្រងប្រតិបត្តិការភតិសន្យាទេ ។ បទពិសោធន៍ពីអន្តរជាតិបង្ហាញថា ប្រតិបត្តិការភតិសន្យា អាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពបាន លុះត្រាតែមានច្បាប់ដែលល្អ និងគ្រប់ជ្រុងជ្រោយមួយសម្រាប់គ្រប់គ្រងប្រតិបត្តិការរបស់វា ។ ច្បាប់ និងបទបញ្ញត្តិគ្រប់គ្រងប្រតិបត្តិការភតិសន្យា គួរតែចែងឱ្យបានច្បាស់ថា តើកិច្ចសន្យានឹងត្រូវដាក់ឱ្យអនុវត្តទៅយ៉ាងដូចម្តេច ប្រសិនបើភតិកៈ (អ្នកជួល) ខកខានមិនបានបង់ប្រាក់ឈ្នួលដែលត្រូវបង់ និងថាតើប្រតិបត្តិការ ភតិសន្យាត្រូវបង់ពន្ធតាមរបៀបណា ។ បច្ចុប្បន្ននេះ កម្ពុជានៅពុំទាន់មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់ ដែលធានាឱ្យភតិបតី (អ្នកជួលឱ្យគេ) អាចយកសម្ភារៈដែលបានជួលមកវិញដោយឆាប់រហ័ស ប្រសិនបើភតិកៈមិនបានគោរពតាមកិច្ចសន្យានោះ ។ ហេតុនេះហើយ ធនាគារភាគច្រើននៅស្ទាក់ស្ទើរក្នុងការអនុវត្តន៍ប្រតិបត្តិការភតិសន្យា ។

ដោយទទួលស្គាល់ពីសារៈសំខាន់ និងសក្តានុពលរបស់វា រដ្ឋាភិបាលបានចាត់ទុកភតិសន្យាថាជាវិស័យអទិភាពមួយ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់ឆ្នាំ២០០៦-២០១៥ ។ ច្បាប់ និងបទបញ្ញត្តិស្តីពីភតិសន្យាត្រូវបានព្រាងឡើង ហើយបច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់នេះនៅរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រីមុននឹងបញ្ជូនទៅសុំការអនុម័តពីសភាជាតិ ។

សាធារណៈជននៅកម្ពុជាយល់ឃើញជាទូទៅថា ប្រព័ន្ធតុលាការកម្ពុជាមិនមានប្រសិទ្ធិភាព ។ ដូច្នេះ ដើម្បីឱ្យភតិសន្យាត្រូវបានប្រើប្រាស់ជាទូទៅជាផលិតផលហិរញ្ញវត្ថុបាននៅកម្ពុជា រដ្ឋាភិបាលត្រូវតែបង្កើតយន្តការមួយ ដើម្បីធ្វើឱ្យប្រាកដថា ច្បាប់ភតិសន្យានេះអាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធិភាព[៣] ។ សេចក្តីព្រាងច្បាប់ស្តីពីភតិសន្យាមានបទបញ្ញត្តិដែលអនុញ្ញាតឱ្យម្ចាស់ទ្រព្យ អាចយកទ្រព្យដែលបានជួលមកវិញយ៉ាងឆាប់រហ័ស និងប្រកបទៅដោយប្រសិទ្ធិភាព ដោយពុំចាំបាច់ឆ្លងកាត់នីតិវិធីតុលាការ ។ បទបញ្ញត្តិទាំងនេះនឹងជួយជម្រុញប្រតិបត្តិការភតិសន្យាឱ្យការរីកចំរើនទៅមុខបាននៅកម្ពុជា ។ លើសពីនេះទៅទៀត គេក៏ត្រូវការអោយមានបទបញ្ញត្តិពន្ធដារដែលនឹងធានាថាប្រតិបត្តិការភតិសន្យា មិនបាត់បង់ផលប្រយោជន៍ពាក់ព័ន្ធនឹងពន្ធដារ ជាពិសេសអាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ និងពន្ធកាត់ទុកធៀបទៅនឹងប្រតិបត្តការផ្តល់ប្រាក់កម្ចីផ្សេងៗទៀត ។

*ធនាគារពាណិជ្ជ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា មានលទ្ធភាពផ្តល់សេវាកម្មភតិសន្យាដល់អតិថិជនបាននៅក្រោម ច្បាប់ស្តីពីធនាគារ ដែលមានជាធរមានសព្វថ្ងៃ ។ ប៉ុន្តែយើងនៅមានក្តីបារម្ភពីរបៀបគិតពន្ធលើប្រតិបត្តិការតិសន្យា ហើយក្តីបារម្ភនេះហើយ ដែលរារាំងអតិថិជនមិនអោយទទួលសេវាផ្នែកភតិសន្យាបាន ។*

**លោក Gary Runciman នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម**
***ANZ Royal Bank***

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាម ដែលបានកើតឡើងអស់រយៈពេលជាច្រើនទសវត្សមក ធនាគារពាណិជ្ជ ចាប់ផ្តើមដំណើរការឡើងវិញ នៅកម្ពុជាក្នុងអំឡុងទសវត្សឆ្នាំ ១៩៩០ ខណៈដែលរដ្ឋាភិបាលបន្តកែលំអតតឈប់ឈរ នូវក្របខ័ណ្ឌច្បាប់ដែលទាក់ទងនឹងវិស័យហិរញ្ញវត្ថុ ។ ទោះជាយ៉ាងណាក្តី ដើម្បីឱ្យឧស្សាហកម្មនេះរីកចំរើនបានតាមសក្តានុពលរបស់ខ្លួន ក្នុងការជួយសហគ្រាសខ្នាតតូច និងមធ្យមពង្រីកអាជីវកម្ម និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ នោះវាទាមទារឱ្យមានការប្រឹងប្រែងបន្ថែមទៀត ។

ព័ត៌មានហិរញ្ញវត្ថុដែលល្អ និងគ្រប់ជ្រុងជ្រោយ នឹងជួយបង្កើនការផ្តល់ប្រាក់កម្ចី ។ ពេលដែលមានព័ត៌មានឥណទាន ដែលគ្រប់ជ្រុងជ្រោយ វានឹងមិនគ្រាន់តែកាត់បន្ថយហានិភ័យរបស់ស្ថាប័នហិរញ្ញវត្ថុក្នុងការផ្តល់ប្រាក់កម្ចីប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងជួយអ្នកដែលមានប្រវត្តិឥណទានល្អ ឱ្យទទួលបាននូវឥណទានក្នុងលក្ខខ័ណ្ឌល្អប្រសើរផងដែរ ។ រដ្ឋាភិបាលគួរឱ្យអាទិភាព ទៅលើច្បាប់ និងបទបញ្ញត្តិនានាដើម្បីគាំទ្រប្រតិបត្តិការរបស់ការិយាល័យឥណទានឯកជន ។

ចំពោះប្រតិបត្តិការដែលមានកិច្ចធានាវិញ ទោះជាមានច្បាប់ហើយក៏ដោយ ភាពមិនចុះសម្រុងគ្នារវាងច្បាប់នេះ និងក្រមរដ្ឋប្បវេណីត្រូវតែដោះស្រាយអោយបានល្អប្រសើរ ដើម្បីធានាថា ស្ថាប័នហិរញ្ញវត្ថុដែលបានទទួលចលនទ្រព្យ និងទ្រព្យអរូបីជាទ្រព្យបញ្ចាំ អាចរឹបអូសយកទ្រព្យទាំងនោះ បានដោយឆាប់រហ័ស នៅពេលអ្នកខ្ចីខកខានមិនបានសងបំណុល ។ បន្ថែមពីលើនេះទៀត ការចុះបញ្ជីតាមអ៊ីនធឺណេត គួរតែត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយឡើង ដើម្បីឱ្យស្ថាប័នហិរញ្ញវត្ថុនានា និងភាគីពាក់ព័ន្ធដទៃទៀតមានទំនុកចិត្ត និងប្រើប្រាស់វាកាន់តែច្រើនឡើង ។

ដើម្បីឱ្យភតិសន្យាសម្រេចបាននូវសក្តានុពលភាពរបស់ខ្លួនពេញលេញក្នុងការផ្តល់ឱ្យសហគ្រាសជំនួញនានានូវបច្ចេកវិទ្យាថ្មីៗ យានយន្ត និងបរិក្ខាផ្សេងៗទៀតដើម្បីពង្រីកប្រតិបត្តិការនោះ គេត្រូវការនូវក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ ដើម្បីធានាថាភតិបតីអាចយកទ្រព្យដែលជួលនោះមកវិញដោយឆាប់រហ័ស នៅពេលដែលភតិកៈមិនបានគោរពតាមកិច្ចសន្យា ហើយការយកពន្ធទៅលើប្រតិបត្តិការភតិសន្យាមានលក្ខណៈសមស្រប ។

នៅពេលដែលមានការិយាល័យឥណទានឯកជន ដែលមានលក្ខណៈពេញលេញ មានការអនុវត្តច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានាប្រកបដោយស្រិទ្ធិភាព និងមានច្បាប់ និងបញ្ញតិទាក់ទងនឹងភតិសន្យាដែលមានប្រសិទ្ធិភាពនោះ សហគ្រាសនានានៅកម្ពុជានឹងមានភាពងាយស្រួលជាងមុនក្នុងការទទួលបានឥណទាន ។ ហើយភាពងាយស្រួលនេះនឹងធ្វើឱ្យសហគ្រាសខ្នាតតូច និងមធ្យមអាចពង្រីកប្រតិបត្តិការរបស់ខ្លួន និងរួមចំណែកបង្កើនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

[៣] ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, កម្មវិធីអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា, *របាយការណ៍ចុងក្រោយសម្រាប់ ជំនួយបច្ចេកទេសលេខ ៤៤៧៦–CAM ³ កម្មវិធីអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា*, ខែសីហា ឆ្នាំ ២០០៦ ។


រក្សាសិទ្ធិ MPDF 2008
Publisher: MPDF No. 70, Norodom Blvd., Phnom Penh
Tel: (855)-23-210-922 Fax: (855)-23-215-157
E-mail: shor@ifc.org Website: www.mpdf.org